# ការបកស្រាយច្បាប់

# ការបកស្រាយច្បាប់

ដោយមេធាវី មាស ប៊ូរ៉ា និង ប្រាក់ សំអាង*

## ១. សេចក្តីផ្តើម

នៅក្នុងសង្គមប្រជាធិបតេយ្យ មានអំណាចបីប្រភេទ ដែលថែងតម្រូវឲ្យមានឯករាជ្យពីគ្នា។[32] នោះគឺអំណាចនីតិប្រតិបត្តិ ជារបស់រដ្ឋាភិបាល ជាអ្នកអនុវត្តច្បាប់។ អំណាចតុលាការ ដែលតុលាការមាន ដូចជាអំណាចបកស្រាយច្បាប់ និងអំណាចនីតិបញ្ញត្តិរបស់សភា ដែលមានតួនាទីធ្វើច្បាប់។ ជាសត្យានុម័ត មនុស្សគ្រប់រូប មិនមានចំណេះដឹងទូលំទូលាយ និងគ្រប់ជ្រុងជ្រោយទេ។ នេះដូចគ្នាដែរសម្រាប់ សមាជិកសភា ទោះបីជាពួកគាត់បានសិក្សាច្បាប់ និងមានសញ្ញាបត្រច្បាប់ក្តី។ អាស្រ័យហេតុនេះ ច្បាប់របស់សភា ពិតជាមិនរួចពីភាពមានចន្លោះខ្វះខាត (legal loopholes)។ តើអ្នកណាជាអ្នកបកស្រាយច្បាប់? តើការបកស្រាយមានវិសាលភាពកម្រិតណា និងវិធីសាស្ត្របកស្រាយអ្វី នឹងត្រូវបានយកមកប្រើ?

អត្ថបទនេះ ព្យាយាមស្រាយបំភ្លឺបញ្ហានេះ ដោយចាប់ផ្តើមការពិនិត្យលើទ្រឹស្តីមួយចំនួនធ្វើការវិភាគ និងដាក់ចេញនូវសេចក្តីសន្និដ្ឋានជាបឋមរួមនឹងអនុសាសន៍ប្រសិនបើមាន។

## ២. ខ្លឹមសារ

### ២.១. ការអនុវត្តជាអន្តរជាតិ

ជាដំបូង សូមពិនិត្យមើលនូវខ្លឹមសារដកស្រង់នៃបទប្បញ្ញត្តិចំនួនពីរ។ ទីមួយ មាត្រា ២ នៃកតិកាសញ្ញាស្តីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយ៖

> *“រដ្ឋជាភាគីនៃកតិកាសញ្ញានេះ ត្រូវធានា និងគោរព នូវសិទ្ធិរបស់ជនគ្រប់រូប នៅក្នុងដែនដី **និង**ក្រោមយុត្តាធិការរបស់ខ្លួន....”*។[33]

---

* **មេធាវី មាស ប៊ូរ៉ា** ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈត្តករពាណិជ្ជកម្ម និងសាស្ត្រាចារ្យច្បាប់។ និង **ប្រាក់ សំអាង** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ ។

[32] រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ របស់កម្ពុជា, មាត្រា ៥១។

[33] Each State Party to the present Covenant undertakes to respect and to ensure to all individuals within its territory and subject to its jurisdiction the rights recognized in the present Covenant, International Covenant on Civil and Political Rights, ICCPR, UN, Treaty Series, Vol. 999, p. 171.

អនុសញ្ញាស្តីពី ច្បាប់សន្ធិសញ្ញា៖ “*សន្ធិសញ្ញា ត្រូវបកស្រាយ ដោយសុទ្ធចិត្តអនុលោមតាមភាសាធម្មតា ផ្តល់ដល់ពាក្យនៃសន្ធិសញ្ញា ក្នុងបរិបទសន្ធិសញ្ញា និងក្នុងខ្លឹមសារនៃកម្មវត្ថុ និងគោលបំណង*”។[34]

ក្នុងករណីសិក្សា មន្ត្រីរាជការរបស់ប្រទេស *ក* បានមកបំពេញការងារ នៅក្នុងប្រទេសកម្ពុជា ហើយបានបំពារបំពានសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។ ប្រជាជនកម្ពុជា បានប្តឹងទៅតុលាការ ប្រទេស *ក* ។ រដ្ឋាភិបាលប្រទេស *ក* តំណាងដោយអាជ្ញាធរ បានការពារខ្លួននៅមុខតុលាការ ប្រទេស *ក* បានអះអាងថា សូមឲ្យតុលាការ ទម្លាក់បណ្តឹងនេះចោលទៅ ដោយសារមាត្រា ២ នៃកតិកាសញ្ញាខាងលើ ដែលប្រទេស *ក* អនុវត្តចំពោះតែការបំពានសិទ្ធិនៅក្នុងដែនដីប្រទេស *ក* និង ក្រោមយុត្តាធិការប្រទេស *ក* តែប៉ុណ្ណោះ។ ពាក្យ “និង” បញ្ជាក់ខ្លឹមសារនេះ។ ប្រទេស *ក* បកស្រាយរបៀបនេះ គឺអនុលោមតាមមាត្រា ៣១ ដកស្រង់ខាងលើ តែផ្តោតទៅលើអត្ថន័យធម្មតារបស់ពាក្យ “និង” តែប៉ុណ្ណោះ។

មេធាវីតំណាងឲ្យពលរដ្ឋកម្ពុជា នៅចំពោះតុលាការប្រទេស *ក* បានតបថា គោលបំណងនៃសន្ធិសញ្ញា សិទ្ធិមនុស្ស គឺការការពារ សិទ្ធិ និងសេរីភាពបុគ្គល ទោះបីការបំពានសិទ្ធិកើតនៅទីណាក៏ដោយ បុគ្គលត្រូវតែទទួលបានយុត្តិធម៌ ហើយអាជ្ញាធរត្រូវតែទទួលខុសត្រូវ។ សិទ្ធិមនុស្សអនុវត្តក្រៅដែនដី (extraterritorial application of human rights norm)។[35]

វាមិនទំនងជាភាគីប្រទេស *ក* ទទួលយកការអះអាងនេះស្រួលៗពេកទេ ហើយពិតជាមាន អំណះអំណាងឆ្លើយតប។ ទោះបីជាយ៉ាងនេះក្តី មេធាវីរបស់ជនរងគ្រោះ អាចពិនិត្យឯកសារកត់ត្រា ប្រវត្តិនៃការចរចារ (drafting record history) ខ្លឹមសារនៃមាត្រា ២ នេះ ដើម្បីបង្ហាញពីចេតនារបស់អ្នករៀបចំ កតិកាសញ្ញានូវអត្ថន័យនៃពាក្យ “និង”។ តាមរយៈការពិនិត្យគាត់អាចរកឃើញថា ១. មិនមានការពិភាក្សានូវអត្ថន័យនៃពាក្យនេះ។ ២. ពាក្យ “និង” មានអត្ថន័យ ស្មើនឹងពាក្យ “ឬ” និង ៣. ពាក្យ “និង” មានន័យថា អ្វីមួយបូកនិងអ្វីមួយ។ សម្រាប់ចំណុចទី៣ ខ្លឹមសារនៃមាត្រា ២ តម្រូវថា ដើម្បីឲ្យរដ្ឋទទួលខុសត្រូវនូវអំពើរបស់អាជ្ញាធរដែលរំលោភសិទ្ធិមនុស្ស លុះត្រាអំពើនោះ កើតមាននៅក្នុងដែនដី និងក្រោមយុត្តាធិការ។ តាមខ្លឹម

[34] A treaty shall be interpreted in good faith in accordance with the ordinary meaning to be given to the terms of the treaty in their context and in the light of its object and purpose, article 31, the Vienna Convention on the Law of Treaties, 1969, UN Treaty Series, Vol 1155, p. 331, Articles 31-33 (VCLT, 1969).

[35] See generally, Cedric Ryngaert, *Clarifying the Extraterritorial Application of the European Convention on Human Rights*, 28 (74) International and European Security Law, 2012; Oona A. Hathaway, *Human Rights Abroad: When Do Human Rights Treaty Obligations Apply Extraterritorially*? Arizona State Law Journal, 2011.

សារមាត្រា ៣១ ដកស្រង់ខាងលើ ចំណុចទី៣ (“និង” មានន័យថា អ្វីមួយបូកនិងអ្វីមួយ) នឹងមិនទទួលយកទេ ដោយសារការបកស្រាយយកខ្លឹមសារពាក្យ ដោយមិនបានពិចារណានូវបរិបទ និងគោលបំណងនៃសន្ធិសញ្ញា។ ដូចនេះ ជំហរទី១ និង ២ ត្រូវបានប្រកាន់យក ដោយសារថា គោលបំណងនៃសន្ធិសញ្ញាស្តីពី សិទ្ធិមនុស្ស គឺការគោរព និងធានានូវសិទ្ធិសេរីភាពមនុស្ស ទាមទារឲ្យមានការបកស្រាយទូលាយ។ បន្ថែមពីលើនេះ ការមិនបាននិយាយដល់ខ្លឹមសារនៃពាក្យ “និង” ក្នុងអំឡុងពេលពិភាក្សាខ្លឹមសារនៃមាត្រា ២ គាំទ្រនូវលទ្ធផលបកស្រាយទូលាយ តាមគោលបំណងនៃសន្ធិសញ្ញា។[36]

ទំនាក់ទំនងរវាងខ្លឹមសារ និងខ្លឹមសារកំណត់ត្រាប្រវត្តិធ្វើសន្ធិសញ្ញា ត្រូវបានលើកឡើងដោយតុលាការយុត្តិធម៌អន្តរជាតិ។ ក្រោយពីបកស្រាយខ្លឹមសារមាត្រាពាក់ព័ន្ធ ហើយសន្និដ្ឋានថា បញ្ញា ឬ វិធានការបណ្តោះអាសន្ន (interim measure) របស់ខ្លួន មានចរិតចងជាកាតព្វកិច្ចដល់ភាគីជម្លោះ តុលាការយុត្តិធម៌អន្តរជាតិ យោងទៅដល់កំណត់ត្រានៃការពិភាក្សាលើមាត្រាពាក់ព័ន្ធ ដែលមិនមាននិយាយ (unclear) អំពីចរិតនៃវិធានការបណ្តោះអាសន្ន បានអះអាងថា ការមិនបានពិភាក្សានេះ មិនខ្វែងនឹង ការរកឃើញរបស់ខ្លួនឡើយ ដូចនេះវិធានការការពារមានចរិតចងជាកាតព្វកិច្ច។[37] ក្នុងន័យនេះ ប្រសិនបើរដ្ឋមិនបានគោរព រដ្ឋនឹងបំពានកាតព្វកិច្ច។

មាត្រាក្នុងសន្ធិសញ្ញា ស្តីពីច្បាប់សន្ធិសញ្ញា បានចែងឲ្យពិនិត្យមើលនូវស្ថានភាព (ជំហររបស់រដ្ឋ) នៅពេលអនុម័តសន្ធិសញ្ញា ព្រមទាំងការអនុវត្តក្រោយមករបស់រដ្ឋ។[38] ក្នុងសំណុំរឿងសន្មត់ខាងលើ គេត្រូវពិនិត្យមើលជំហររបស់ប្រទេស *ក* ថាតើកន្លងប្រទេសនេះបានបកស្រាយ ពាក្យ “និង” មានន័យយ៉ាងណា?។

ខាងលើវាជាទ្រឹស្តី ក៏ប៉ុន្តែ ការអនុវត្តជាក់ស្តែងពាក់ព័ន្ធនឹងការបកស្រាយសន្ធិសញ្ញាដោយរដ្ឋមានភាពខុសគ្នាជាខ្លាំង។ ប្រទេសខ្លះ ក្នុងការបកស្រាយសន្ធិសញ្ញាសិទ្ធិមនុស្ស

[36] States Parties are required by article 2, paragraph 1, to respect and to ensure the Covenant rights to all persons who may be within their territory and to all persons subject to their jurisdiction. This means that a State party must respect and ensure the rights laid down in the Covenant to anyone within the power or effective control of that State Party, even if not situated within the territory of the State Party, Human Rights Committee, General Comment No. 31 on the Nature and the General Obligation Imposed on States Parties to the Covenant, CCPR/C/21/Rev.1/Add.13, 26 May 2004, para.10.

[37] The Rules of the International Court of Justice, at www.icj-cij.org/documents. LAGRANT Case (Germany v. United States of America), Summary of 27 June 2001 Judgment, pp. 195-196, at www.icj-cij.org

[38] VCLT, *supra note* 3, Article 31.

អះអាងថា មានការរំពឹងទុកស្របច្បាប់ (legitimate expectation)[39] ថា ការចូលជាភាគីសន្ធិសញ្ញាណាមួយ រដ្ឋ ឬរដ្ឋាភិបាលនឹងអនុវត្តសន្ធិសញ្ញានោះ ដោយសុទ្ធចិត្ត (good faith)។[40] អាស្រ័យហេតុនេះ តុលាការត្រូវបកស្រាយច្បាប់ជាតិយ៉ាងណាឲ្យអនុលោមតាមច្បាប់អន្តរជាតិ (presumption of conformity)។ នេះ ជាពិសេស សម្រាប់ការបកស្រាយនូវសន្ធិសញ្ញា ដែលមិនទាន់ក្លាយជាផ្នែកមួយនៃច្បាប់ជាតិ (unin-corporated treaties) របស់ប្រទេស Common Law។[41] ជំហរដែលថា ការបកស្រាយច្បាប់ ជាតិឲ្យស្របនឹងច្បាប់អន្តរជាតិហាក់ជាជំហរទូទៅ។[42] ក្នុងការបកស្រាយ ប្រសិនបើការបកស្រាយ ចេញជា ខ្លឹមសារពីរ ខ្លឹមសារដែលស្រប ឬកៀកកិតនឹងកាតព្វកិច្ចអន្តរជាតិគួរត្រូវបានប្រកាន់យក។[43] តុលាការនៃប្រទេសខ្លះនឹងប្រកាន់យកខ្លឹមសារត្រង់នៃពាក្យ ទោះបីមានអត្ថន័យផ្ទុយនឹងគោលបំណង ឬកាតព្វកិច្ចក្នុងសន្ធិសញ្ញាក្តី ដោយផ្អែកថា វាជាចេតនារបស់សភា ដែលតម្រូវឲ្យតុលាការបកស្រាយយ៉ាងនេះ។[44] នេះទំនងជា តុលាការមិនចង់បំពាននូវតួនាទីរបស់សភា តាមទ្រឹស្តីនៃការបែងចែកអំណាច។[45] ក្នុង

[39] *Id.*,

[40] *Id.*, article 27, VCLT, *supra* note 3.

[41] David Sloss, the Role of Domestic Courts in Treaty Enforcement, A Comparative Study, 2009, p. 5. ប្រកាន់យកនូវការសន្មត់របៀបនេះ នៅពេលដែលច្បាប់ជាតិមានខ្លឹមសារមិនច្បាស់ សូមមើល David Sloss, Domestic Application of Treaties, 2011,p.14 http://digitalcommons.law .scu.edu/facpubs/635.

[42] Gib van Ert, *Canada*, p. 188 *in* David Sloss, the Role of Domestic Courts in Treaty Enforcement, A Comparative Study, 2009។ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ កបធ.ច ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧ បង្ហាញពីទំនាក់ទំនង រវាងច្បាប់កម្ពុជា និងសន្ធិសញ្ញា។ ទោះបីជាយ៉ាងនេះក្តី វាមានភាពមិនច្បាស់ ថា កម្ពុជា ប្រកាន់ យកការសន្មតដូចនេះដែរឬទេ ដោយសារ ក្រុមប្រឹក្សា គ្រាន់តែអះអាងថា តុលាការត្រូវប្រើច្បាប់ ដែលរាប់បញ្ចូល សន្ធិសញ្ញា ដែលកម្ពុជាទទួលស្គាល់។ *យល់ឃើញថា ជាគោលការណ៍ ក្នុងការជំនុំជម្រះក្តី ចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា៨ នៃច្បាប់ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋតែមួយនេះទេដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវផ្អែកលើច្បាប់។ ពាក្យថាច្បាប់ខាងលើនេះ មានន័យថា ច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលនៅជាធរមាន ហើយនិងច្បាប់អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ។*

[43] Nihal Jayawickrama, India, *in* David Sloss, the Role of Domestic Courts in Treaty Enforcement, A Comparative Study, 2009, p. 249.

[44] Gib van Ert, *Canada*, p. 189 *in* David Sloss, the Role of Domestic Courts in Treaty Enforcement, A Comparative Study, 2009.

[45] Andreas L. Paulus, Germany, p.215 *in* David Sloss, the Role of Domestic Courts in Treaty Enforcement, A Comparative Study, 2009.

វិស័យសិទ្ធិមនុស្ស សិទ្ធិជាវិធាន ទាមទារឲ្យមានការបកស្រាយឲ្យទូលាយ។ ផ្ទុយទៅវិញ ការកម្រិតសិទ្ធិគឺជាករណីលើកលែង ដែលទាមទារឲ្យការកម្រិតសិទ្ធិ ត្រូវបកស្រាយឲ្យចង្អៀត។[46]

តុលាការប្រទេសបារាំង មានអំណាចបកស្រាយសន្ធិសញ្ញា និងសុំយោបល់យល់ឃើញពីក្រសួងការបរទេស ក្នុងករណីប្រយោជន៍សាធារណៈអាចមានហានិភ័យ ក្នុងការបកស្រាយសន្ធិសញ្ញា (public interest is at stake)។[47] តុលាការនឹងបកស្រាយសន្ធិសញ្ញា ក៏ប៉ុន្តែតុលាការនឹងស្នើសុំយោបល់របស់រដ្ឋាភិបាល ហើយយោបល់នេះអាចត្រូវបានគោរពដោយតុលាការ (deference)។[48]

គំនិតជាតិនិយម (nationalist approach) មានឥទ្ធិពលដល់ការបកស្រាយរបស់តុលាការប្រទេសខ្លះ ដូចជាអាមេរិក ឬ អ៊ីស្រាអែល។[49] នេះក្នុងន័យថា ច្បាប់ជាតិ នឹងត្រូវបានផ្តល់តម្លៃខ្ពស់ជាងក្នុងពេលមានទំនាស់រវាងបទប្បញ្ញត្តិច្បាប់ជាតិ និងច្បាប់អន្តរជាតិ ឬការបកស្រាយថា សន្ធិសញ្ញាមិនផ្តល់សិទ្ធិដល់បុគ្គលជាជនរងគ្រោះ ធ្វើពាក្យបណ្តឹងសុំសំណងពីអំពើរបស់អាជ្ញាធរ ដែលបំពានកាតព្វកិច្ច ក្នុងសន្ធិសញ្ញាពាក់ព័ន្ធ។

បញ្ហាបន្ទាប់ ថាតើអ្នកណាជាអ្នកកំណត់វិធីសាស្ត្របកប្រែណាមួយ? នៅក្នុងនីតិវិធីចំពោះមុខតុលាការ ច្បាប់ដែលអនុវត្ត (applicable law) និងវិធីសាស្ត្របកស្រាយ (interpretative approach) ណាមួយដែលនឹងប្រកាន់យក ពិតជាពាក់ព័ន្ធយ៉ាងខ្លាំងនឹងលទ្ធផលនៃក្តីក្តាំ។ អាស្រ័យហេតុនេះ រដ្ឋជាភាគីជម្លោះ ពិតជាប្រឹងខ្លាំងណាស់ក្នុងការអន្ទងឲ្យតុលាការយកច្បាប់ ឬវិធីបកស្រាយដែលខ្លួនចង់បាន។ ភាគីអាចគិតថា វិធីបកស្រាយតាមមាត្រា ៣១ នៃសន្ធិសញ្ញាស្តីពីច្បាប់សន្ធិសញ្ញា អាចនាំឲ្យមានហានិភ័យដល់ខ្លួន។ ដូចនេះ ភាគីអះអាងថា រដ្ឋខ្លួនមិនមែនជាភាគីនៃសន្ធិសញ្ញានេះទេ។ តុលាការអាចអះអាងតបវិញថា

[46] ‘There are other general legal principles for interpretation that should also be considered, such as the interpretative principle that limitation provisions shall be construed and applied in a restrictive way’, *interpretation of human rights treaties,* available at http://www.humanrights.is/en/human-rights-education-project/human-rights-concepts-ideas-and-fora/part-i-the-concept-of-human-rights/interpretation-of-human-rights-treaties.

[47] Pierre Michel Eisemann and Raphaele Rivier, *France*, p. 270 *in* Duncan B. Hollis, Merritt R. Blakeslee and L. Benjamin Ederington, National Treaty Law and Practice, Dedicated to the Memory of Monroe Leigh, 2005.

[48] John Dugard, *South Africa*, pp. 471-472 *in* David Sloss, the Role of Domestic Courts in Treaty Enforcement, A Comparative Study, 2009.

[49] David Sloss, the Role of Domestic Courts in Treaty Enforcement, A Comparative Study, 2009, p. 28.

វិធានបកស្រាយ ចែងក្នុងសន្ធិសញ្ញានេះ វាជាវិធានទំនៀមទម្លាប់អន្តរជាតិ ចងកាតព្វកិច្ចដោយស្វ័យប្រវត្តិ (automatically binding) ដោយមិនចាំបាច់ចូលជាភាគី ឬទទួលយកទេ។[50]

## ២.២. ការអនុវត្តរបស់តុលាការក្នុងស្រុក

ប្រទេសខ្លះ មានច្បាប់ ឬបទប្បញ្ញត្តិណែនាំសម្រាប់ការបកស្រាយច្បាប់។[51] ដូចគ្នានឹងការអនុវត្តក្នុងការបកស្រាយសន្ធិសញ្ញាដែរ តុលាការនឹងពិនិត្យមើលអត្ថន័យនៃពាក្យជាដំបូង គោលបំណង និងវិធានដទៃ ឬ ទ្រឹស្តីមួយចំនួនទៀត ដែលពាក់ព័ន្ធជាក្រោយ។

ជាការពិតណាស់ ប្រសិនបើពាក្យពេចន៍ខ្លឹមសារច្បាស់ តុលាការនឹងប្រកាន់យកខ្លឹមសារនេះ។ ឧទហរណ៍ បទប្បញ្ញត្តិបានចែងថា ជនណាម្នាក់នឹងមានទោស ប្រសិន បើបើកបររថយន្ត ក្នុងទីក្រុងលើសពី៤០គីឡូម៉ែត្រក្នុងមួយម៉ោង។[52] *ប្រសិនបើពាក្យ នៃច្បាប់ច្បាស់លាស់ ដូចនេះមិនចាំបាច់បកស្រាយពាក្យទាំងនោះ...។ ពាក្យទាំងនោះតែឯង បង្ហាញចេតនាដ៏ជាក់លាក់របស់អ្នកធ្វើច្បាប់។*[53]ក្នុងករណីមិនច្បាស់ តុលាការខ្លះ ដូចជាអង់គ្លេស អនុវត្តនូវវិធាន Mischief Rule។[54]

ឧទាហរណ៍ច្បាប់បានចែងថា នារីរកស៊ីផ្លូវភេទ ដែលបោយដៃហៅបុរសនៅតាមដងផ្លូវនឹងទទួលទោស។ វាអាចមានការបកស្រាយថា មានទោសលុះត្រានារីនោះ ឈរនៅលើដងផ្លូវ មិនមែនឈរនៅលើយ៉មុខក្នុងផ្ទះ បោយដៃហៅបុរសទេ។ តាមវិធាន Mischief ការបកស្រាយចង្អៀតរបៀបនេះ នឹងមិនទទួលយកទេ។ សភាពិចារណាថា អំពើពេស្យាចារបង្ករផលវិបាកក្នុងសង្គមច្រើន ដូចជាប៉ះពាល់ដល់សណ្តាប់ធ្នាប់ ឬសីលធម៌សាធារណៈ ដូចនេះសភាធ្វើច្បាប់

---

[50] David Kretzmer, Israel, p.278, *in* David Sloss, the Role of Domestic Courts in Treaty Enforcement, A Comparative Study, 2009; Articles 31 and 32 of the Vienna Convention on the Law of Treaties set forth, respectively, the general rule of interpretation and the rule on supplementary means of interpretation. These rules also apply as customary international law, the United Nations, Report of the Office of Legal Affairs, legal.un.org/ilc/reports/2016/english/chp6.pdf

[51] Australia, Interpretation Act 1901 (Cth), s 15AB (2)(d).

[52] មាត្រា៦២ នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោកឆ្នាំ ២០១៤៖ *មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកមានសិទ្ធិដកបណ្ណបើកបរព្យួរទុក ...ចំពោះបទល្មើសណាមួយដូចខាងក្រោម...២. បើកបរដោយល្បឿនលើសចាប់ពី ៤០ (សែសិប) គីឡូម៉ែត្រក្នុងមួយម៉ោងឡើងទៅ ពីល្បឿន ដែលបានកំណត់ក្នុងច្បាប់នេះ។*

[53] *If the words of the statute are in themselves precise and unambiguous, then no more can be necessary than to expound those words in their natural and ordinary sense. The words themselves alone do, in such a case, best declare the intention of the lawgiver*, see Sussex Peerage Case (1884) 8 ER 1034.

[54]Ian Mcleod, Legal Method, 5th Ed., 2005, pp. 253-263.

ដើម្បីបំពេញចន្លោះខ្វះខាតក្នុងឯកសារច្បាប់មុន ក្នុងបំណងដើម្បីលុបបំបាត់ទាំងស្រុងនៃអំពើពេស្យាចារ។ អាស្រ័យហេតុនេះ ការបោយដៃរបស់ស្ត្រីពេស្យាចារ ទោះបីនៅទីណា ក៏មានទោសដែរ។[55] វិធាននេះ វាស្រដៀងគ្នានឹង វិធានបកស្រាយតាមគោលបំណងដែរ ក៏ប៉ុន្តែវិធានចុងក្រោយនេះ តុលាការនឹងពិនិត្យមើលខ្លឹមសារក្នុងច្បាប់ ដើម្បីរកនូវបំណងច្បាប់។ វិធានទាំងពីរនេះ ប្តុំបញ្ចូលគ្នាទំនងជានឹងបង្កើតនូវវិធានបកស្រាយទូលាយ (broad interpretation)។[56] វិធានបកស្រាយទូលាយ តម្រូវឲ្យមានការយោងដល់បទដ្ឋានគតិយុត្តិទូលំទូលាយ របស់ជាតិ ឬអន្តរជាតិ។ តុលាការកំពូលកម្ពុជា ក្នុងរឿងដ៏ល្បីល្បាញមួយ បានប្រកាន់យកវិធីសាស្ត្របកស្រាយទូលាយ៖

> *"ចម្លើយសារភាពមិនត្រូវជាភស្តុតាងដាក់បន្ទុកសំខាន់ទេ...តាមស្មារតីមាត្រា ១៤ ចំណុចទី៣ ឆ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយបានកំណត់ថាជនជាប់ចោទគ្រប់រូបមានសិទ្ធិមិនឲ្យនរណាបង្ខិតបង្ខំឲ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬទទួលសារភាពនូវកំហុសដែលមិនត្រឹមត្រូវនោះទេ ដែលបទដ្ឋានអន្តរ ជាតិ នេះ ត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១...។ ចម្លើយសារភាពមិនស៊ីសង្វាក់គ្នាទៅនឹងដើមកំណើតនៃភស្តុតាង និងទំនងជាធ្វើឲ្យប៉ះពាល់សុច្ចរិតភាពនៃដំណើរការរឿងក្តីផងដែរ។ ...តាមសំអាងហេតុចុងក្រោយនៃ សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ កបធ.ច ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញ បានសំអាងថា ចៅក្រមជំនុំជម្រះក្តីផ្អែកលើច្បាប់ ជាតិរួមមានរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់...។ មាត្រា ៦៩ នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ (ដែលកម្ពុជាជាភាគី) បានកំណត់ថា ភស្តុតាងដែលទំនងជាប្រឆាំងដល់នឹងបង្កព្យសនកម្ម ដល់ភាពសុច្ចរិតនៃដំណើរការក្តី*

[55] Smith v. Hughes [1960] 1 WLR 830, *see* E-Lawresources, http://www.e-lawresources.co.uk/Smith-v-Hughes-%5B1960%5D.php.

[56] Nick Park, A Broad and Generous Interpretation of Human Rights, *available at* http://www.vox.ie/001/2017/1/30/a-broad-and-generous-interpretation-of-human-rights. *Nachova and et al. v. Bulgaria*, European Court of Human Rights, Application Nos. 43577/98; 43579/98, Judgement of 26 February 2004, para. 168.

*មិនត្រូវទទួលយកបានឡើយ។ ...ភស្តុតាងជាចម្លើយសារភាពបែបនេះមិនអាចមានតម្លៃជាភស្តុតាងដាក់បន្ទុកបានឡើយ។*[57]

ស្រដៀងគ្នានេះ តុលាការកាណាដាបានអះអាង៖ *វិធីសាស្ត្រទំនើបក្នុងការបកស្រាយច្បាប់ ដែលអនុលោមតាមវិធីនេះ ពាក្យនៃច្បាប់ត្រូវបានពិចារណាក្នុងបរិបទទាំងស្រុង និងខ្លឹមសារតាមន័យធម្មតា និងវេយ្យាករណ៍ស្របនឹងទម្រង់នៃច្បាប់ គោលបំណងនៃច្បាប់ ព្រមទាំងចេតនារបស់សភា"*[58]

ក្រៅពីវិធានខាងលើ តុលាការនឹងពិចារណា នូវទ្រឹស្តីពាក់ព័ន្ធមួយចំនួនទៀត ដូចជា ឋានានុក្រមនៃច្បាប់ (ច្បាប់ធម្មនុញ្ញជាច្បាប់កំពូលខ្ពស់ជាងច្បាប់ទាំងឡាយ)[59] ការបកស្រាយច្បាប់ព្រហ្មទណ្ឌ តឹងរឹងមិនតាមសទិសភាព។ "*ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ*"។[60] ហើយករណីមន្ទិល ត្រូវផ្តល់ប្រយោជន៍ដល់ជនសង្ស័យ។ "*វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*"។[61] ទំនាក់ ទំនងរវាងច្បាប់ពិសេស និងច្បាប់ទូទៅ (*lex specialis v. lex generalis*)[62] ច្បាប់កើតមុន និងកើតក្រោយ (*lex postia*)[63] ពាក្យសំដែងនូវកាតព្វកិច្ច (shall)[64] ឬអនុសាសន៍ (should)[65] ពាក្យមាន ដូចជា(such as) ដែលបង្ហាញពីឧទាហរណ៍។ មាត្រាទី២ នៃកតិកាសញ្ញា សិទ្ធិប្រជាពលរដ្ឋ និងនយោបាយ បានចែងនូវមូលហេតុនៃការរើសអើង ដូចជា ភេទ សាសនា តែមិនបានដាក់បញ្ចូល ពិការភាពជាមួយហេតុទេ។[66] គណៈ

---

[57] សាលដីកាតុលាការកំពូល សំណុំរឿងព្រហ្មទណ្ឌ សាលដីកាលេខ ២៣៩ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣។

[58] *The so called modern approach to statutory interpretation, according to which the words of an Act are be read in their entire context and in their grammatical and ordinary sense harmoniously with the scheme of the Act, the object of the Act, and the intention of Parliament, see* Rizzo & Rizzo Shoes Ltd. (Re) [1998] 1 SCR 27, at para. 21.

[59] Cambodian Constitutional Council, Decision no. 092/003/2007, *supra* note 11; 1993 Cambodian Constitution, Article 131.

[60] 2009 Cambodian Criminal Code, Article 5.

[61] 1993 Cambodian Constitution, Article 38, *supra* note 28.

[62] Ashika Singh, *the United States, the Torture Convention, and Lex Specialis: the Quest for A Coherent Approach to the CAT in Armed Conflict*, 47 (3) Columbia Human Rights Law Review, 2016, p. 141; Alejandro Lorite Escorihuela, *Humanitarian Law and Human Rights Law: the Politics of Distinction*, 19(2) Michigan State Journal of International Law, 2011, p.360.

[63] Emily S. Bremer, *the Dynamic Last-In-Time Rule*, Ind. Int'L & Comp. L. Rev, 2012, p. 31.

[64] LAGRANT Case (Germany v. United States of America), Summary of 27 June 2001 Judgment, pp. 195-196, at www.icj-cij.org;

[65] *Id.*

[66] *Article 2:1. Each State Party to the present Covenant undertakes to respect and to ensure to all individuals within its territory and subject to its jurisdiction the rights recognized in the present Covenant, without distinction of any kind, such as race, colour, sex, language, religion, political or other*

កម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានអះអាងថាពាក្យ ដូចជា (such as) ជាពាក្យមានខ្លឹមសារទូលាយក្តោបមូលហេតុពិការភាពផងដែរ។[67]

ការបកស្រាយខ្លឹមសារនៃពាក្យពេចន៍ ក៏ត្រូវពិនិត្យ ពាក្យក្នុងចង្កោមពាក្យ ឧទាហរណ៍ កាំភ្លើងខ្លី ឬវែងក្តី សុទ្ធតែជាអាវុធ អាចសម្លាប់មនុស្សបាន។[68] ឯកសារច្បាប់មានភាពវិវត្ត (living instrument) ដែលត្រូវបកស្រាយតម្រូវតាម ស្ថានភាពបច្ចុប្បន្ន។ នេះជាទ្រឹស្តី ផ្តួចផ្តើមដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប ថាសិទ្ធិមនុស្សមានការវិវត្ត (dynamic) បកស្រាយមាត្រា ៣ ដែលចែងហាមឃាត់អំពើទារុណកម្ម រាប់បញ្ចូលការហាមឃាត់បញ្ជូនជនណាមួយទៅជួបអំពើទារុណកម្ម។ ការបកស្រាយនេះ ឆ្លើយតបនឹងទៅការបកស្រាយរបស់ អង់គ្លេសថាមាត្រា ៣ (ហាមឃាត់អំពើទារុណកម្ម) នៃសន្ធិសញ្ញា សិទ្ធិមនុស្សអឺរ៉ុប មិនបានចែងហាមបញ្ជូនឧក្រិដ្ឋជនទៅជួបហានិភ័យ នៃអំពើទារុណកម្មទេ។[69]

ក្នុងការបកស្រាយ តុលាការប្រទេសខ្លះ បានពិចារណាលើការអនុវត្ត ឬការបកស្រាយរបស់តុលាការបរទេសផងដែរ។ នៅក្នុងសេចក្តីសម្រេច លើរឿងក្តីបត្យាប័នស្នើដោយសហរដ្ឋអាមេរិក ដល់ប្រទេស កាណាដា តុលាការកំពូលរបស់ កាណាដា បានពិចារណាយ៉ាងស៊ីជម្រៅពាក់ព័ន្ធជាមួយនឹងច្បាប់សន្ធិសញ្ញា សាលក្រមរបស់តុលាការអន្តរជាតិ និងរបស់ជាតិ ព្រមទាំងឯកសារផ្សេងៗទៀត ដែលជាប់ទាក់ទិន ជាមួយការហាមឃាត់ទោសប្រហារជីវិត។ តុលាការកំពូលរបស់កាណាដា បានរកឃើញនូវនិន្នាការទូទៅនៃការលុបចោល ឬការមិនប្រើទោសប្រហារជីវិត។ ផ្អែកតាមគំហើញនេះ តុលាការបានតម្រូវឲ្យរដ្ឋាភិបាលកាណាដា សុំការធានាពីសហរដ្ឋអាមេរិក មិនឲ្យប្រើទោសប្រហារជីវិតលើជន ដែលកាណាដាបញ្ជូនទៅវិញ នៅក្នុងគ្រប់

*opinion, national or social origin, property, birth or other status, see ICCPR, supra note* 2. The English will be "such as"non-exhaustive, see *prohibited grounds of non-discrimination*, available at http://www.humanrights.is/en/human-rights-education-project/comparative-analysis-of-selected-case-law-achpr-iachr-echr-hrc/the-right-to-equality-and-non-discrimination/prohibited-grounds-of-discrimination.

[67] Article 2(2) lists the prohibited grounds of discrimination as "race, colour, sex, language, religion, political or other opinion, national or social origin, property, birth or other status". The inclusion of "other status" indicates that this list is not exhaustive and other grounds may be incorporated in this category. The express grounds and a number of implied grounds under "other status" are discussed below, see the Committee on Economic, Social and Cultural Rights, E/C.12/GC/20, 10 June 2009, para. 15.

[68] Jacob Scott, *Codified Canons and the Common Law of Interpretation*, 98(341) the Georgetown Law Journal, 2010, p. 354.

[69] *Soering v. the United Kingdom*, No. 14038/88 [1989] ECHR 14 (July 7, 1989), *para*. 101.

ករណីបត្យាប័នទាំងអស់ ពាក់ព័ន្ធទោសប្រហារជីវិត។[70] តុលាការ ទាមទារយ៉ាងនេះ នាំឲ្យមានការផ្លាស់ប្តូរទម្លាប់ ដែលរដ្ឋាភិបាលកាណាដា សុំនូវការធានា កុំឲ្យមានទោសប្រហារជីវិត ក្នុងតែករណីចាំបាច់ និងពិសេសតែប៉ុណ្ណោះ ។ ការទាមទារដូចនេះ គឺដើម្បីឲ្យសម ស្របតាមខ្លឹមសារដែលទាមទារ ក្នុងសន្ធិសញ្ញាបត្យាប័នរវាងកាណាដា និងសហរដ្ឋអាមេរិក ជួយ បញ្ចៀសកុំឲ្យមានការរំលោភសិទ្ធិមនុស្ស និងជាពិសេស កុំឲ្យមានការរំលោភច្បាប់របស់ កាណាដា ដែលលុបចោលទោសប្រហារជីវិត។[71] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ក្នុងការពិចារណាថា តើការបង្ខំ (duress) ជាមូលហេតុឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌក្នុងបទមនុស្សឃាតបានធ្វើការអង្កេតនូវច្បាប់ និងសាលក្រមរបស់ប្រទេសមួយចំនួន ដូចជាសហរដ្ឋអាមេរិក ម៉ាឡេស៊ីជាដើម។[72]

## ៣. សង្ខេប

ជាការឆ្លើយតបនឹងចន្លោះខ្វះខាតនៃច្បាប់ តុលាការជាតិ និងអន្តរជាតិ មានអំណាចបកស្រាយច្បាប់ ហាក់ប្រកាន់យកនូវវិធីសាស្ត្របកស្រាយទូលាយ (គោលបំណងនៃសន្ធិសញ្ញា និងច្បាប់)។ ចេតនារបស់អ្នកធ្វើច្បាប់ហាក់មិនត្រូវបានផ្តល់តម្លៃ នេះដូចគ្នានៃខ្លឹមសារនៃឯកសារកំណត់ត្រានៃការធ្វើច្បាប់។ ទោះបីជាយ៉ាងនេះក្តី ឯកសារទាំងនោះ និងចេតនា ក៏ត្រូវបានពិចារណាផងដែរ។ តុលាការពិចារណានូវពាក្យពេចន៍ក្នុងបរិបទ និងបំណងនៃច្បាប់ពិនិត្យមាត្រាជាច្រើនដែលពាក់ព័ន្ធ សូម្បីមាត្រាក្នុងច្បាប់ផ្សេងក្តីក្នុងចេតនារកឲ្យឃើញនូវខ្លឹមសារពិតអព្យាក្រឹត មិនអយុត្តិធម៌ខ្លាំងពេកចំពោះភាគីណាមួយ ដែលធ្វើឲ្យទាំងអ្នកចាញ់ និងឈ្នះសុទ្ធតែទទួលយកបាន។

---

[70] Human Rights Committee, Judge v. Canada, CCPR/C/78/D/829/1998, 13 August 2003; Supreme Court of Canada, United States v. Burns, [2001] 1 SCR 283, para. 91.

[71] Supreme Court of Canada, United States v. Burns, [2001] 1 SCR 283, para. 131.

[72] Prosecutor v. Erdemovic´, Case No. IT-96-22-A, Joint Separate Opinion of Judge McDonald and Judge Vohrah, ¶¶ 57–58 (Int'l Crim. Trib. for the Former Yugoslavia Oct. 7, 1997), *at* http://www.icty.org/x/cases/erdemovic/acjug/en/erd-asojmcd971007e.pdf, see as well, Neha Jain, *Comparative International Law at the ICTY: The General Principles Experiment*, 109 Am. J. Int'l L. 486 (2015), *available at* http://scholarship.law.umn.edu/faculty_articles/427.